# គោលនយោបាយ RIDOT

## យោងៈចំណងជើង VI/ការមិនរើសអើង

គោលនយោបាយរបស់នាយកដ្ឋានដឹកជញ្ជូននៃរដ្ឋ Rhode Island (នាយកដ្ឋាន) គឺអនុវត្តទាំងស្រុងតាមចំណងជើង VI នៃច្បាប់ស្តីពីសិទ្ធិស៊ីវិលឆ្នាំ 1964 និងការធានារ៉ាប់រងលើកម្មវិធីចំណងជើង VI /ការមិនការរើសអើងរបស់នាយកដ្ឋាននេះ។ ដើម្បីសម្រេចគោលដៅនោះ នាយកដ្ឋាននេះបញ្ជាក់ថា គ្មានបុគ្គលណាម្នាក់នៅក្នុងសហរដ្ឋអាមេរិកត្រូវបានហាមមិនឲ្យចូលរួម ត្រូវបានបដិសេធមិនឲ្យទទួលអត្ថប្រយោជន៍ ឬទទួលរងនូវការរើសអើងដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ដើមកំណើតជាតិសាសន៍ អាយុ ឬពិការភាព ក្រោមកម្មវិធី ឬសកម្មភាពណាមួយរបស់នាយកដ្ឋាន មិនថាកម្មវិធី និងសកម្មភាពទាំងនោះទទួលបាន ឬមិនទទួលបានជំនួយហិរញ្ញវត្ថុសហព័ន្ធនោះទេ។

ជាពិសេស នាយកដ្ឋាន**នឹងមិនត្រូវ**អនុវត្តដូចខាងក្រោមផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ដើមកំណើតជាតិសាសន៍ អាយុ ឬពិការភាពៈ

- បដិសេធមិនផ្តល់សេវាកម្ម ជំនួយហិរញ្ញវត្ថុ ណាមួយ ឬអត្ថប្រយោជន៍ផ្សេងទៀតដល់អ្នកទទួលផលពីកម្មវិធីរបស់នាយកដ្ឋាន
- ផ្តល់សេវាកម្ម ជំនួយហិរញ្ញវត្ថុ ឬអត្ថប្រយោជន៍ណាមួយដែលខុសគ្នាត្រង់ផ្នែក—គុណភាព បរិមាណ ឬលក្ខណៈ— ខុសពីអ្វីដែលផ្តល់ជូនអ្នកទទួលផលផ្សេងទៀត នៅក្រោមកម្មវិធីរបស់នាយកដ្ឋាន
- ប្រព្រឹត្តចំពោះបុគ្គលណាម្នាក់ដោយមានការបែងចែកឬដាច់ដោយឡែកពីគ្នាក្នុងបញ្ហាណាមួយដែលទាក់ទងទៅនឹងការទទួលបានសេវាកម្ម ជំនួយហិរញ្ញវត្ថុ ឬអត្ថប្រយោជន៍ផ្សេងទៀតដែលស្ថិតនៅក្រោមកម្មវិធីរបស់នាយកដ្ឋាន
- ប្រព្រឹត្តចំពោះបុគ្គលណាម្នាក់ខុសពីអ្នកដទៃក្នុងការកំណត់ថាតើបុគ្គលនោះមានសិទ្ធិឬអត់ក្នុងការទទួលបានសេវាកម្ម ជំនួយហិរញ្ញវត្ថុ ឬអត្ថប្រយោជន៍ផ្សេងទៀត នៅក្រោមកម្មវិធីរបស់នាយកដ្ឋាន
- រឹតបន្តឹងបុគ្គលណាម្នាក់ក្នុងការអាស្រ័យផលពីអត្ថប្រយោជន៍ ឬឯកសិទ្ធិណាមួយដែលអ្នកដទៃអាស្រ័យផលដែលទទួលបានសេវាកម្ម ជំនួយហិរញ្ញវត្ថុ ឬអត្ថប្រយោជន៍ផ្សេងទៀតនៃកម្មវិធីរបស់នាយកដ្ឋាន
- បដិសេធបុគ្គលណាម្នាក់មិនឱ្យមានឱកាសចូលរួមក្នុងក្រុមប្រឹក្សារៀបចំផែនការ ឬផ្តល់ប្រឹក្សាយោបល់ដែលជាផ្នែកសំខាន់មួយនៃកម្មវិធីរបស់នាយកដ្ឋាន
- រើសអើងក្នុងសកម្មភាពណាមួយដែលពាក់ព័ន្ធនឹងផ្លូវហាយវេ អគារ ឬហេដ្ឋារចនាសម្ព័ន្ធដែលបានកសាង ឬជួសជុលដោយប្រើមូលនិធិសហព័ន្ធ

- រើសអើងក្នុងការងារណាមួយដែលនាំឲ្យមានកម្មវិធីមួយដែលមានគោលបំណងចម្បងនៃការផ្តល់ការងារ ឬ
- រើសអើងក្នុងការជ្រើសរើស និងការរក្សាអ្នកម៉ៅការ និងអ្នកផ្តល់ប្រឹក្សា។

លើសពីនេះទៅទៀត នាយកដ្ឋាននឹងមិនគ្រប់គ្រងកម្មវិធីរបស់ខ្លួនក្នុងលក្ខណៈដោយផ្ទាល់ ឬតាមរយៈកិច្ចសន្យា ដែលបំផ្លាញ ឬធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលដៅរបស់ខ្លួននៃការមិនរើសអើងដែលចូលជាធរមាន។ ផ្ទុយទៅវិញ នាយកដ្ឋាននឹងកំណត់ និងដោះស្រាយផលប៉ះពាល់នៃកម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ខ្លួនស្តីពីប្រជាជនភាគតិច និងប្រជាជនដែលមានចំណូលទាប ព្រមទាំងផ្តល់ជូននូវសិទ្ធិចម្បងក្នុងការទទួលបានអត្ថប្រយោជន៍ព័ត៌មាន និងសេវាកម្មដល់អ្នកទទួលផលដែលមានសមត្ថភាពនិយាយភាសាអង់គ្លេសមានកម្រិត។ បុគ្គលណាម្នាក់ដែលមានសំណួរ ឬស្វែងរកព័ត៌មានបន្ថែមអំពីកាតព្វកិច្ចមិនរើសអើងរបស់នាយដ្ឋាន គួរតែទាក់ទង Solight Sou អ្នកសម្របសម្រួលផ្នែកចំណងជើង VI តាមអាសយដ្ឋាន៖ 2 Capitol Hill, Providence, Rhode Island 02903 (401) 222-3260, លេខទូរស័ព្ទភ្ជាប់បន្ត៖4256 ឬអ៊ីម៉ែល៖ solight.sou @dot.ri.gov។ ស្រដៀងគ្នានេះផងដែរ បុគ្គលណាម្នាក់ដែលជឿថា នាយកដ្ឋាន ឬអ្នកទទួលភារកិច្ចបន្ត ឬអ្នកម៉ៅការរបស់នាយកដ្ឋានបានរំលោភលើចំណងជើង VI នៃច្បាប់ស្តីពីសិទ្ធិស៊ីវិល ឆ្នាំ 1964 ឬគោលនយោបាយស្តីពីការមិនរើសអើងនេះ គួរតែទាក់ទងអ្នកសម្របសម្រួលផ្នែកចំណងជើង VI របស់ នាយកដ្ឋាន ដើម្បីដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ។